ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខ: ៤៤៩៩ សសរ

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតក្រុមការងារតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើ ការរៀបចំ និងការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញសេចក្តីសម្រេចលេខ០៩៧ សសរ/គ.ជ.អ.ប. ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ស្តីពីការដាក់ឱ្យប្រើប្រាស់សៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់
- យោងតាមការចាំបាច់របស់ក្រសួងមហាផ្ទៃ

## សម្រេច

**ប្រការ១.**_

បង្កើតក្រុមការងារតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការរៀបចំ និងការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ក្នុងក្របខណ្ឌទូទាំងប្រទេស ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **សូស ច្រាថ្លា** | អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល | ប្រធាន |
| ២-ឯកឧត្តម | **ជា ម៉ុនហេង** | អគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាល | អនុប្រធាន |
| ៣-ឯកឧត្តម | **រស់ រតនៈ** | អគ្គាធិការរងនៃអគ្គាធិការដ្ឋាន | អនុប្រធាន |

| | | | |
|---|---|---|---|
| ៤-ឯកឧត្តម | **លី ប៊ុនថៃ** | ទីប្រឹក្សាក្រសួងមហាផ្ទៃ | សមាជិក |
| ៥-លោក | **លី យ៉ាសាក់** | ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ | សមាជិក |
| ៦-លោក | **ឃុំ ម៉េងស៊ាន** | ប្រធានក្រុមសវនកម្មផ្ទៃក្នុង នៃលេខាធិការដ្ឋាន គ.ជ.អ.ប. | សមាជិក |
| ៧-លោក | **មាស ឈីវហ៊ុន** | អនុប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ | សមាជិក |
| ៨-លោក | **ប៊ិត ចាន់ខន** | អនុប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ | សមាជិក |
| ៩-លោក | **សរ សុវណ្ណឬទ្ធិ** | ប្រធានការិយាល័យ នៃនាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ | សមាជិក |
| ១០-លោក | **យាន យក់ធិន** | ប្រធានការិយាល័យហិរញ្ញវត្ថុ និងផែនការរដ្ឋបាលថ្នាក់ក្រោមជាតិ នៃលេខាធិការដ្ឋាន គ.ជ.អ.ប. | សមាជិក |
| ១១-លោក | **គួច សំអឿន** | អនុប្រធានការិយាល័យ នៃនាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ | សមាជិក |
| ១២-លោក | **ហុក សុខម៉េង** | អនុប្រធានការិយាល័យ នៃនាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ | សមាជិក |
| ១៣-លោក | **សុខ ភាន់ទាន់** | អនុប្រធានការិយាល័យ នៃនាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ | សមាជិក |
| ១៤-លោក | **ថាច់ សាទី** | ទីប្រឹក្សាហិរញ្ញវត្ថុ នៃលេខាធិការដ្ឋាន គ.ជ.អ.ប. | សមាជិក |
| ១៥-កញ្ញា | **ពៅ រតនា** | មន្ត្រីនាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុកឃុំ សង្កាត់ | សមាជិក |

**ប្រការ២._**

ក្រុមការងារតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការរៀបចំ និងការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ទូទាំងប្រទេស មានតួនាទី និងភារកិច្ចសំខាន់ៗដូចខាងក្រោម៖

- ធ្វើជាសេនាធិការជូនរដ្ឋមន្ត្រី ក្នុងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការរៀបចំ និងអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ ដើម្បីលើកកម្ពស់គុណភាព ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងបរិយាបន្ន
- ត្រួតពិនិត្យការរៀបចំបញ្ជីឈ្មោះអ្នកទទួលការប្រចាំឆ្នាំរបស់រដ្ឋបាលរាជធានី ខេត្ត
- ត្រួតពិនិត្យការរៀបចំឯកសារសំណើគម្រោង និងឯកសារកិច្ចសន្យាគម្រោង
- តាមដាន និងវាយតម្លៃលើការប្រកាសជូនដំណឹងស្តីពីការដេញថ្លៃគម្រោងមូលនិធិឃុំ សង្កាត់ ទាំងនៅតាមសាលាឃុំ សង្កាត់ សាលាក្រុង ស្រុក ខណ្ឌ សាលារាជធានី ខេត្ត និងនៅលើគេហទំព័រ គ.ជ.អ.ប.
- តាមដាន និងវាយតម្លៃលើការរៀបចំកិច្ចប្រជុំបើកសំណើដេញថ្លៃគម្រោងមូលនិធិឃុំ សង្កាត់
- សហការតាមដាន និងត្រួតពិនិត្យគុណភាព និងបរិមាណនៃលទ្ធផលគម្រោងមូលនិធិឃុំ សង្កាត់
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការចាត់វិធានការរបស់រដ្ឋបាលរាជធានី ខេត្តចំពោះអ្នកទទួលការដែលអនុវត្តមិនស្របតាមកិច្ចសន្យា ឬមិនស្របតាមសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់

- ពិនិត្យលើកយោបល់ក្នុងការកែសម្រួលទម្រង់ បែបបទ និងនីតិវិធីនៃការរៀបចំ និងការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ ឱ្យមានស្តង់ដារួម មានភាពសាមញ្ញ និងងាយស្រួល
- សិក្សាស្រាវជ្រាវ តាមដាន និងត្រួតពិនិត្យភាពមិនប្រក្រតីនានាដែលបានចុះផ្សាយក្នុងសារព័ត៌មាន ឬ/និងបណ្តាញសង្គមនានា
- សហការជាមួយក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ក្នុងការសិក្សាស្រាវជ្រាវ តាមដាន និងត្រួតពិនិត្យពាក់ព័ន្ធនឹងភាពមិនប្រក្រតីនៃការរៀបចំ និងការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់
- លើកយោបល់ជូនថ្នាក់ដឹកនាំក្រសួងមហាផ្ទៃដាក់វិន័យ ឬទណ្ឌកម្មលើមន្ត្រីរូបណាដែលមានការពាក់ព័ន្ធនឹងភាពមិនប្រក្រតីនៃការរៀបចំ និងការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- បំពេញកិច្ចការចាំបាច់ផ្សេងៗទៀតតាមការប្រគល់ភារកិច្ចពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**ប្រការ៣._**

ក្រុមការងារតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការរៀបចំ និងការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ ទូទាំងប្រទេស មានសិទ្ធិប្រើប្រាស់មធ្យោបាយ និងថវិការបស់អង្គភាពសាមីរៀងៗខ្លួនដើម្បីអនុវត្តភារកិច្ចការងារដែលថ្នាក់ដឹកនាំបានប្រគល់ជូន។

**ប្រការ៤._**

រាល់សេចក្តីសម្រេចទាំងឡាយណាដែលផ្ទុយពីសេចក្តីសម្រេចនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៥._**

អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប. និងសាមីខ្លួនដូចមានឈ្មោះក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៦រោច ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**អភិសន្តិបណ្ឌិត ស សុខា**

**កន្លែងទទួល ÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ដូចប្រការ៥
- ឯកសារ កាលប្បវត្តិ